ក

មាតិកា

I~ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៦-៦-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៦០៧/២២០ ស្ដីពីការតម្លើងឋានន្តរស័ក្ដិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ	៤៣៦៨
០៧-៦-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៦០៧/២២២ ស្ដីពីការប្រគល់ភារកិច្ចជូនឯកឧត្ដម **ខិក សុផុន** ឱ្យបំពេញមុខងារជា អគ្គនាយក នៃអគ្គនាយកដ្ឋានបេតិកភណ្ឌ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ	៤៣៦៩
១០-៦-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៦០៧/២២៥ ស្ដីពីការតែងតាំងឯកឧត្ដម និងលោកជំទាវ ចំនួន ២៨ រូប ជាទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល	៤៣៧០
១០-៦-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៦០៧/២២៦ ស្ដីពីការតែងតាំងឯកឧត្ដម **ឡាយ ព្រហស្ស** ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី	៤៣៧២
១០-៦-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៦០៧/២២៨ ស្ដីពីការតែងតាំងឥស្សរជន ជាសមាជិកនៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំ នៃកម្ពុជា សម្រាប់អាណត្តិទី ២	៤៣៧៤
១០-៦-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៦០៧/២២៩ ស្ដីពីការបំពាក់គ្រឿង ឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ជូននាយអាវុធហត្ថ ០៦ រូប ដែលមានគុណបំណាច់ខ្ពស់ ក្នុងការបំរើជាតិមាតុភូមិ និងរួមចំណែកជួយអភិវឌ្ឍ កសាងកងយោធពលខេមរភូមិន្ទ	៤២៧៥
១០-៦-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៦០៧/២៣១ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ នាយទាហានជាន់ខ្ពស់ ចំនួន ២៦ រូប	៤៣៧៦

II~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

១១-៦-២០០៧	-អនុក្រឹត្យ លេខ ៥៨ អនក្រ.បក ស្ដីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់	៤៣៧៨

១២-៦-២០០៧ -អនុក្រឹត្យ លេខ ៥៩ អនក្រ.បក ស្តីពីការទទួលស្គាល់សាកលវិទ្យាល័យ ឡាយហ្វ ៤៣៨១

១២-៦-២០០៧ -អនុក្រឹត្យ លេខ ៦០ អនក្រ.បក ស្តីពីអគ្គសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ៤៣៨៤

១១-៦-២០០៧ -អនុក្រឹត្យលេខ ៤៥៦ អនក្រ.តត ស្តីពីការកំណត់ក្របខ័ណ្ឌមន្ត្រីក្រមការ និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យមតាមលក្ខន្តិកៈដោយឡែក ៤៣៨៧

១១-៦-២០០៧ -អនុក្រឹត្យលេខ ៤៥៧ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៤៤០៤

១២-៦-២០០៧ -អនុក្រឹត្យលេខ ៤៥៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៤៤០៥

១២-៦-២០០៧ -អនុក្រឹត្យលេខ ៤៥៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៤៤០៦

១២-៦-២០០៧ -អនុក្រឹត្យលេខ ៤៦០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៤៤០៦

២.សេចក្តីសំរេច

១១-៦-២០០៧ -សេចក្តីសំរេចលេខ ២៩ សសរ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការសម្របសម្រួល និងគ្រប់គ្រងគម្រោងផ្លូវជាតិលេខ ៣ ពីចោមចៅ (ភ្នំពេញ) ទៅដល់ទីរួមខេត្តកំពត ៤៤១០

១៣-៦-២០០៧ -សេចក្តីសំរេចលេខ ៣០ សសរ ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៤៤១២

III.ការងារបណ្តាក្រសួង

១.ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

០៧-៦-២០០៧ -ប្រកាសលេខ ៥២៤ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ជីក្វាន អ៊ិនធើណេសិនណល (ខេមបូឌា) អិលធីឌី បង្កើតរោងចក្រ " ផលិតសំពត់ជំរំ (Tent) " ដែលមានឈ្មោះថា " ជីក្វាន អ៊ិនធើ ណេសិនណល (ខេមបូឌា) អិលធីឌី " ៤៤១៣

១២-៦-២០០៧ -ប្រកាសលេខ ៥៣៥ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អង្គរ ឃែនវើស ខូ អិលធីឌី បង្កើតរោងចក្រ " ផលិតស៊ុមរូបថត និងស៊ុមផ្ទាំងគំនូរ " ដែលមានឈ្មោះថា " អង្គរ ឃែនវើស ខូ អិលធីឌី " ៤៤១៥

១២-៦-២០០៧ -ប្រកាសលេខ ៥៣៦ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ណាក់ហ្គេត តេចស្តាយ (ភីធីអ៊ី) អិលធីឌី បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា " ណាក់ហ្គេត តេចស្តាយ (ភីធីអ៊ី) អិលធីឌី " ៤៤១៧

១២-៦-២០០៧ -ប្រកាសលេខ ៥៣៧ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ភ្នំពេញ ហាន់នី ប្រដាក់ (ខេមបូឌា) ខូ អិលធីឌី បង្កើតរោងចក្រ " កែច្នៃទឹកឃ្មុំ " ដែលមានឈ្មោះថា " ភ្នំពេញ ហាន់នី ប្រដាក់ (ខេមបូឌា) ខូ អិលធីឌី " ៤៤១៩

២. លិខិតបញ្ជាក់ក្រសួងពាណិជ្ជកម្ម

០១-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៥១៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ត្រានរូមី អ៊ិមផត អិចផត & ត្រេនស្តិត** ៤៤២១

០១-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៥២០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទិកថឺរ ជេ (ធី.ជី.)** ៤៤២៣

០១-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៥២២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិល អិន គី ឌីវេឡុបមេន** ៤៤២៥

០១-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៥២៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មានមូ** ៤៤២៧

០១-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៥២៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេព សាទេត អ៊ិមផត អិចផត** ៤៤២៩

០១-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៥២៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភាណាឌីយ៉ា អ៊ិនវេសមេន ហូលឌីង គ.ស** ៤៤៣១

០១-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៥៣០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ ឌី ស៊ី អ៊ិនធើណេសិនណល** ៤៤៣៣

០១-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៥៣១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មុខ មុខ ទើលដ៏ អ៊ិនវេសមេន & ខនសាល់ធីង គ្រុប** ៤៤៣៥

០១-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៥៣៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សេខ ធី.គី.** ៤៤៣៧

០៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៥៤២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ាឡា ម៉ាច ខ្មែរ អ៊ិនវេសមេន** ៤៤៣៩

០៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៥៤៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជ្រៃឃ្លាន~ត្រាវិច គៀន** ៤៤៤១

០៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៥៤៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស៊ា ហ្វូឈីដេ ត្រាវ៉ែល & ធួរ (ខេមបូឌា)** ៤៤៤៣

ព្រះរាជក្រឹត្យ

នស/រកត/០៦០៧/២២០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ព្រះរាជបញ្ជាប់

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានឈ្មោះខាងក្រោម :

ក_ឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ឯក :

- លោកឧត្តមសេនីយ៍ទោ ម៉ាន់ ឆាយ អត្តលេខ ០២០៣

ខ_ឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ :

១- លោកឧត្តមសេនីយ៍ត្រី ទៃ ស៊ុណារិទ្ធ អត្តលេខ ០២៣៣
២- លោកឧត្តមសេនីយ៍ត្រី មិត គីមឃុន អត្តលេខ ០៣៤៩
៣- លោកឧត្តមសេនីយ៍ត្រី ឯក ក្រឹស្ន អត្តលេខ ០៣៤៧
៤- លោកឧត្តមសេនីយ៍ត្រី ពេជ្រ ជីវ័ន្ត អត្តលេខ ០១០២

គ_ឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ត្រី :

១- លោកវរសេនីយ៍ឯក អ៊ិន ឫទ្ធី អត្តលេខ ០២១០
២- លោកវរសេនីយ៍ឯក នួន សារិន អត្តលេខ ០៥០៤

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៧

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣.៧.០៧០៦.២៣២

លេខ:២២៧៦.៧

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៦០៧/២២២

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម **ឱក សុផុន** ឱ្យបំពេញមុខងារជា **អគ្គនាយក នៃអគ្គនាយកដ្ឋានបេតិកភណ្ឌ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** ។

មាត្រា២: បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៣: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៤: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៧

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រល.០៧០៦.២៣៤

លេខៈ ២៣១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៦០៧/២២៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោមនេះ:

១-ឯកឧត្តម គីង សំណាង ជាទីប្រឹក្សាឯកឧត្តម កែម ពុទ្ធរស្មី ឧបនាយករដ្ឋមន្ត្រី ឋានៈស្មើ រដ្ឋលេខាធិការ

២-ឯកឧត្តម សំ សារ៉េត ជាទីប្រឹក្សាឯកឧត្តម កែម ពុទ្ធរស្មី ឧបនាយករដ្ឋមន្ត្រី ឋានៈស្មើ រដ្ឋលេខាធិការ

៣-លោកជំទាវ សុខណ្ណ មុនុម ជាទីប្រឹក្សាឯកឧត្តម កែម ពុទ្ធរស្មី ឧបនាយករដ្ឋមន្ត្រី ឋានៈស្មើ រដ្ឋលេខាធិការ

៤-ឯកឧត្តម អ៊ុំ ឈឿន ជាទីប្រឹក្សាឯកឧត្តម កែម ពុទ្ធរស្មី ឧបនាយករដ្ឋមន្ត្រី ឋានៈស្មើ អនុរដ្ឋលេខាធិការ

៥-ឯកឧត្តម យឹម សំអឿន ជាទីប្រឹក្សាឯកឧត្តម លឺ ឡាយស្រេង ឧបនាយករដ្ឋមន្ត្រី ឋានៈស្មើ រដ្ឋលេខាធិការ

៦-ឯកឧត្តម ឡឹក ជូណាល់ ជាទីប្រឹក្សាឯកឧត្តម លឺ ឡាយស្រេង ឧបនាយករដ្ឋមន្ត្រី ឋានៈស្មើ រដ្ឋលេខាធិការ

៧-ឯកឧត្តម ភុល ខុន្លា ជាទីប្រឹក្សាឯកឧត្តម លឺ ឡាយស្រេង ឧបនាយករដ្ឋមន្ត្រី ឋានៈស្មើ អនុរដ្ឋលេខាធិការ

៨-ឯកឧត្តម សុន អរុណ ជាទីប្រឹក្សាឯកឧត្តម ញឹក ប៊ុនឆៃ ឧបនាយករដ្ឋមន្ត្រី ឋានៈស្មើ រដ្ឋលេខាធិការ

៩-ឯកឧត្តម សេង ហាក់ស្រ៊ុន ជាទីប្រឹក្សាឯកឧត្តម ញឹក ប៊ុនឆៃ ឧបនាយករដ្ឋមន្ត្រី ឋានៈស្មើ រដ្ឋលេខាធិការ

១០-ឯកឧត្តម អ៊ិត សារិ ជាទីប្រឹក្សាឯកឧត្តម ញឹក ប៊ុនឆៃ ឧបនាយករដ្ឋមន្ត្រី ឋានៈស្មើ រដ្ឋលេខាធិការ

១១-ឯកឧត្តម ឈឹម រតនៈ ជាទីប្រឹក្សាឯកឧត្តម ញឹក ប៊ុនឆៃ ឧបនាយករដ្ឋមន្ត្រី ឋានៈស្មើ រដ្ឋលេខាធិការ

១២-ឯកឧត្តម ហ៊ីង ខុឌី ជាទីប្រឹក្សាព្រះអង្គម្ចាស់ក្សត្រីយ៍ នរោត្តម ម៉ារីរណឫទ្ធិទេសរដ្ឋមន្ត្រី ឋានៈស្មើអនុរដ្ឋលេខាធិការ

១៣-ឯកឧត្តម មាន សំរេច ជាទីប្រឹក្សាព្រះអង្គម្ចាស់ក្សត្រីយ៍ នរោត្តម ម៉ារីរណឫទ្ធិ ទេសរដ្ឋមន្ត្រី ឋានៈស្មើអនុរដ្ឋលេខាធិការ

១៤- ឯកឧត្តម ជួន សាទុង ជាទីប្រឹក្សាព្រះអង្គម្ចាស់ក្សត្រីយ៍ នរោត្តម ម៉ារីរណាឫទ្ធិទេសរដ្ឋមន្ត្រី ឋានៈស្មើអនុរដ្ឋលេខាធិការ

១៥- ឯកឧត្តម គីម ស៊ីន ជាទីប្រឹក្សាឯកឧត្តម វេង សិរីវុឌ្ឍ ទេសរដ្ឋមន្ត្រី ឋានៈស្មើ អនុរដ្ឋលេខាធិការ

១៦- ឯកឧត្តម មុំ អោម ជាទីប្រឹក្សាឯកឧត្តម វេង សិរីវុឌ្ឍ ទេសរដ្ឋមន្ត្រី ឋានៈស្មើ អនុរដ្ឋលេខាធិការ

១៧- ឯកឧត្តម ម៉ែន សំអាត ជាទីប្រឹក្សាឯកឧត្តម កុល ផេង ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឋានៈស្មើ អនុរដ្ឋលេខាធិការ

១៨- ឯកឧត្តម អ៊ុក ស៊ុយ ជាទីប្រឹក្សាឯកឧត្តម កុល ផេង ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឋានៈស្មើ អនុរដ្ឋលេខាធិការ

១៩- ឯកឧត្តម សំ ឈឹម ជាទីប្រឹក្សាឯកឧត្តម ឃី តាំងលីម ទេសរដ្ឋមន្ត្រី ឋានៈស្មើ អនុរដ្ឋលេខាធិការ

២០- ឯកឧត្តម ប្រឹម សំបូរ ជាទីប្រឹក្សាឯកឧត្តម ឃី តាំងលីម ទេសរដ្ឋមន្ត្រី ឋានៈស្មើ អនុរដ្ឋលេខាធិការ

២១- ឯកឧត្តម អ៊ឹម ស៊ី ជាទីប្រឹក្សាអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ប៉ាណារ៉ាសិរីវុឌ្ឍ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ឋានៈស្មើ អនុរដ្ឋលេខាធិការ

២២- ឯកឧត្តម គីម នៃហ៊ាង ជាទីប្រឹក្សាអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ប៉ាណារ៉ាសិរីវុឌ្ឍរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឋានៈស្មើ អនុរដ្ឋលេខាធិការ

២៣- ឯកឧត្តម មូល ឈឿន ជាទីប្រឹក្សាឯកឧត្តម ស៊ុន ចាន់ថុល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឋានៈស្មើអនុរដ្ឋលេខាធិការ

២៤- ឯកឧត្តម ជួប សឿន ជាទីប្រឹក្សាឯកឧត្តម ស៊ុន ចាន់ថុល រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន ឋានៈស្មើ អនុរដ្ឋលេខាធិការ

២៥- ឯកឧត្តម ម៉ែន សក្តា ជាទីប្រឹក្សាឯកឧត្តម នុត សុខុម រដ្ឋមន្ត្រី ក្រសួងសុខាភិបាល ឋានៈស្មើ អនុរដ្ឋលេខាធិការ

២៦- ឯកឧត្តម ចណ្ណ សារ៉ាយ ជាទីប្រឹក្សាឯកឧត្តម នុត សុខុម រដ្ឋមន្ត្រី ក្រសួងសុខាភិបាល ឋានៈស្មើ អនុរដ្ឋលេខាធិការ

២៧- ឯកឧត្តម ស្វាត្រ ស៊ុផល ជាទីប្រឹក្សាលោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី ឋានៈស្មើ អនុរដ្ឋលេខាធិការ

២៨- ឯកឧត្តម ហង្ស លុច ជាទីប្រឹក្សាលោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ឋានៈស្មើ អនុរដ្ឋលេខាធិការ

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០៧

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

នស/រកត.០៦០៧.២៣៧

លេខ ២៣៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេង

ព្រះរាជក្រឹត្យ

នស/រកត/០៦០៧/២២៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: ត្រូវបានតែងតាំងឯកឧត្តម ឡាយ ព្រហស្ស ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី ។

មាត្រា២: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៧
ព្រះបរមនាម នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
ព្រះមហាក្សត្រ ដើម្បីឡាយព្រះហស្ថលេខា

ជំនួសព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣រល.០៧០៦.២៣៤

លេខ:២៣៦ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
យុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៦០៧/២២៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៦០៣/១៩១ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការតែងតាំងប្រធាន អនុប្រធាន និងសមាជិក គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការកែសម្រួល មាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និង មាត្រា១៦ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១.-

ត្រូវបានតែងតាំងឥស្សរជន ដូចមានរាយនាមខាងក្រោម ជាសមាជិកនៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា សម្រាប់អាណត្តិទី២ ÷

១- ឯកឧត្តម **សេង លឹមនៅ**	រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី
២- ឯកឧត្តម **ភាន់ ម៉ែន**	រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី
៣- ឯកឧត្តម **ហង់ ជួន ណារ៉ុន**	អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៤- ឯកឧត្តម **យូឃាង ចាវរិទ្ធ**	សមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
៥- ឯកឧត្តម **ឆយ អូន**	សមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

មាត្រា២.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣.-

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៤.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១០ ខែ មិថុនា ឆ្នាំ ២០០៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

នស/រកត.០៦០៧.២៤០

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

លេខៈ ៤២៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០០៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៦០៧/២២៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : បំពាក់គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ជូននាយអាវុធហត្ថ ០៦ រូប ដែលមានគុណបំណាច់ខ្ពស់ ក្នុងការបំរើជាតិមាតុភូមិ និងរួមចំណែកជួយអភិវឌ្ឍ កសាងកងយោធពលខេមរភូមិន្ទ ដូចមានរាយនាមខាងក្រោម ÷

ក. <u>មេដាយថ្នាក់មហាសេនា</u>

- វរសេនីយ៍ឯក រ័ត្ន ស្រ៊ាង អត្តលេខ ០០៤៥៥៨

ខ. <u>មេដាយថ្នាក់សេនា</u>

១-វរសេនីយ៍ឯក ម៉ិន សាម៉ុន អត្តលេខ ០០១១៣២
២-វរសេនីយ៍ឯក ឆៅ ចណ្ណះ អត្តលេខ ០០១១៣១
៣-វរសេនីយ៍ឯក ទី សារិទ្ធ អត្តលេខ ០០២៥៧៣
៤-វរសេនីយ៍ឯក ពុទ្ធ សារ៉ាន់ អត្តលេខ ០០០៤៩០
៥-វរសេនីយ៍ឯក ឡា ខៀ អត្តលេខ ០០០៤៣៧

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវ ព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រ.ល. ០៧០៦.២៤១

លេខ:២៣៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០០៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៦០៧/២៣១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ

ចំពោះ

១-ឧត្តមសេនីយ៍ត្រី អ៊ុក ផល្លី អត្តលេខ ០០១២១៧
២-ឧត្តមសេនីយ៍ត្រី ហាន់ សុវណ្ណា អត្តលេខ ០០១៨៧៨
៣-ឧត្តមសេនីយ៍ត្រី ចាន់ នន់វិទ្យា អត្តលេខ ០០៣៤៥៩
៤-ឧត្តមសេនីយ៍ត្រី អ៊ី សុខ អត្តលេខ ០០៣៤៦១
៥-ឧត្តមសេនីយ៍ត្រី ម៉ា ចន្ថា អត្តលេខ ០០១២០៤
៦-ឧត្តមសេនីយ៍ត្រី តែម ម៉ឺន អត្តលេខ ០០២០៣៥
៧-ឧត្តមសេនីយ៍ត្រី ព្រាប សាលី អត្តលេខ ០០០៦៤១
៨-ឧត្តមសេនីយ៍ត្រី ទី វណ្ណី អត្តលេខ ០០០៥៥០
៩-ឧត្តមសេនីយ៍ត្រី អ៊ុច សុវណ្ណា អត្តលេខ ០០១៩៦៩
១០-ឧត្តមសេនីយ៍ត្រី នេប សន អត្តលេខ ០០០៨១៧
១១-ឧត្តមសេនីយ៍ត្រី ជា សារ៉ាយ អត្តលេខ ០០១២៥៣
១២-ឧត្តមសេនីយ៍ត្រី ញាណ្ណា មនោ អត្តលេខ ០០០៦៨៤
១៣-ឧត្តមសេនីយ៍ត្រី សៅ សេង អត្តលេខ ០០៣៥៣៨
១៤-ឧត្តមសេនីយ៍ត្រី ម៉ុង ដារ៉ិន អត្តលេខ ០០១១៣៨
១៥-ឧត្តមសេនីយ៍ត្រី ហ៊ុង វិណ្ណុល អត្តលេខ ០០៥២៣៦
១៦-ឧត្តមសេនីយ៍ត្រី សុខ មុន្នី អត្តលេខ ០១១៦១២

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

១៧-ឧត្តមសេនីយ៍ត្រី ខៀវ សារ៉េត អត្តលេខ ០០១៧៣២
១៨-ឧត្តមសេនីយ៍ត្រី ស្រ៊ុន គីមស្រៀង អត្តលេខ ០០៥១៦៥
១៩-ឧត្តមសេនីយ៍ត្រី សៀ សម្បត្តិ អត្តលេខ ០០៣៣៨៣
២០-ឧត្តមសេនីយ៍ត្រី ភួង ស៊ីគិន អត្តលេខ ០០២៥៦៨
២១-ឧត្តមសេនីយ៍ត្រី ឃួន វណ្ណអេ អត្តលេខ ០០២៥៥០
២២-ឧត្តមសេនីយ៍ត្រី តួច តារា អត្តលេខ ០០០៨៥៦
២៣-ឧត្តមសេនីយ៍ត្រី ទ៊ា ស៊ិនភីរម្យ អត្តលេខ ០០៥១៦១
២៤-ឧត្តមសេនីយ៍ត្រី ហែម ណាង អត្តលេខ ០០២៥៦៣
២៥-ឧត្តមសេនីយ៍ត្រី ឌៀវ ម៉ុនខេង អត្តលេខ ០០៤២៤៦
២៦-ឧត្តមសេនីយ៍ត្រី សួង ពុទ្ធា អត្តលេខ ០០១៧៤០

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣រ.ល.០៧០៦.២៤៣

លេខ: ២៧៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ.ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ជីនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

មាត្រា ១.-

ត្រូវបានបង្កើតគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម លឹម គានហោ	រដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម	ប្រធាន
២- ឯកឧត្តម សំ សារិត	រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម	អនុប្រធាន
៣- ឯកឧត្តម ទុំ ស៊ីម៉ុន	រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន	អនុប្រធាន
៤- ឯកឧត្តម ឆា ជុប	អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន	សមាជិក
៥- ឯកឧត្តម ព្រហ្ម សិទ្ធត្រា	អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
៦- ឯកឧត្តម សុខ ឡេង	អគ្គនាយកធនធានរ៉ែ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបង្កើតគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

មាត្រា ១.-

ត្រូវបានបង្កើតគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម លឹម គានហោ	រដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម	ប្រធាន
២- ឯកឧត្តម សំ សារិត	រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម	អនុប្រធាន
៣- ឯកឧត្តម ម៉ុម ស៊ីប៊ុន	រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន	អនុប្រធាន
៤- ឯកឧត្តម ឆា ដុច	អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន	សមាជិក
៥- ឯកឧត្តម ព្រហ្ម សិទ្ធត្រា	អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
៦- ឯកឧត្តម សុខ ឡេង	អគ្គនាយកធនធានរ៉ែ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក

៧- ឯកឧត្តម សួន សិទ្ធី	អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
៨- ឯកឧត្តម ណៅ ធូក	ប្រធានរដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
៩- ឯកឧត្តម ថាច់ ឃន	អភិបាលខេត្តកំពត	សមាជិក
១០- ឯកឧត្តម ម៉ាន់ ឆ្វាង សុផាន់	អភិបាលរងរាជធានីភ្នំពេញ	សមាជិក
១១- ឯកឧត្តម ម៉ៅ តិរុណ	អភិបាលរងខេត្តកណ្តាល	សមាជិក
១២- ឯកឧត្តម ស៊ឹម សុខគ្រី	អភិបាលរងខេត្តកំពង់ចាម	សមាជិក
១៣- ឯកឧត្តម ចំនួ សំអាន	អភិបាលរងខេត្តសៀមរាប	សមាជិក
១៤- ឯកឧត្តម ឆាំវ ហមផាន	អភិបាលរងខេត្តកំពង់ឆ្នាំង	សមាជិក
១៥- ឯកឧត្តម ឱុច សារុន	អភិបាលរងខេត្តកំពង់ស្ពឺ	សមាជិក
១៦- ឯកឧត្តម ខួយ សុខា	អភិបាលរងខេត្តស្វាយរៀង	សមាជិក
១៧- ឯកឧត្តម ស៊ុន សុខន	អភិបាលរងក្រុងព្រះសីហនុ	សមាជិក
១៨- លោក ខាង ហ៊ឹម	អភិបាលរងខេត្តព្រៃវែង	សមាជិក
១៩- លោក ឆី គីមគុក	អភិបាលរងខេត្តពោធិសាត់	សមាជិក
២០- លោក សៀង ស៊ុតថន	អភិបាលរងខេត្តបាត់ដំបង	សមាជិក
២១- លោក ធុន គ្រី	អភិបាលរងខេត្តក្រចេះ	សមាជិក
២២- លោក ទិន សំអុល	អភិបាលរងខេត្តកោះកុង	សមាជិក
២៣- លោក គិន ណែត	អភិបាលរងខេត្តតាកែវ	សមាជិក
២៤- លោក ជុំ ជាតិ	អភិបាលរងខេត្តឧត្តរមានជ័យ	សមាជិក
២៥- លោក ឆាយ ទិត	អភិបាលរងខេត្តស្ទឹងត្រែង	សមាជិក
២៦- លោក ឈុន ឈន់	អភិបាលរងខេត្តកំពង់ធំ	សមាជិក

មាត្រា ២.-

គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ មានភារកិច្ចដូចតទៅ :

- ជាសេនាធិការផ្ទាល់របស់សម្តេចនាយករដ្ឋមន្ត្រី ដែលជាប្រមុខរាជរដ្ឋាភិបាល ដើម្បីត្រួតពិនិត្យ និងតាមដានលើការធ្វើអាជីវកម្មខ្សាច់ ទាំងអាជីវកម្មនាំចេញ ទាំងអាជីវកម្មសម្រាប់ប្រើប្រាស់ក្នុងស្រុក
- ចុះសិក្សា និងកំណត់ទីតាំងតាមលក្ខណៈបច្ចេកទេសច្បាស់លាស់ មុននឹងអនុញ្ញាតឱ្យធ្វើអាជីវកម្ម ដោយចៀសវាងបាននូវមហន្តរាយផ្សេងៗ ដែលអាចកើតមានឡើង
- សិក្សាពីលទ្ធភាពបូមដី ទន្លេ ស្ទឹង ដើម្បីចាក់បំពេញបឹងបួរបម្រើដល់ការអភិវឌ្ឍក្នុងក្របខណ្ឌទូទាំងប្រទេស
- ពិនិត្យ និងលើកយោបល់សុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល ដើម្បីលុបចោលនូវអាជ្ញាប័ណ្ណសម្រាប់ធ្វើអាជីវកម្មរបស់ក្រុមហ៊ុន អាជីវករ ដែលមិនអនុវត្តតាមការសម្រេចរបស់ គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់
- ធ្វើរបាយការណ៍ពីលទ្ធផលការងារដែលអនុវត្តបាន ជូនប្រមុខរាជរដ្ឋាភិបាល ។

មាត្រា ៣.-

គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងធនធានទឹក និងឧតុនិយម លើរាល់លិខិតស្នាម និងមានថវិកាដោយឡែកសម្រាប់ការងាររបស់ខ្លួន ដែលភ្ជាប់ទៅនឹងគណនីរបស់ក្រសួងធនធានទឹក និងឧតុនិយម ។

គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

មាត្រា ៤.-

គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ មានលេខាធិការដ្ឋានមួយ ជាជំនួយការការងារ ដែលមានទីតាំងនៅទីស្តីការក្រសួងធនធានទឹក និងឧតុនិយម ។ លេខាធិការដ្ឋាននេះ ត្រូវដឹកនាំដោយប្រធានមួយរូប និងជំនួយការមួយចំនួនតាមការចាំបាច់ ។ មន្ត្រីជំនួយការក្នុងលេខាធិការដ្ឋាននេះ ជាមន្ត្រីរបស់ក្រសួងធនធានទឹក និងឧតុនិយម ឬជាមន្ត្រីក្របខ័ណ្ឌមកពីក្រសួង-ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដែលទទួលការតែងតាំងពីប្រធានគណៈកម្មាធិការ ។

មាត្រា ៥.-

លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់មានភារកិច្ចដូចតទៅ :

-ជាសេនាធិការឱ្យគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់

-ទទួលរៀបចំផែនការការងារនិងកិច្ចប្រជុំរបស់គណៈកម្មាធិការ

-សម្របសម្រួល និងទំនាក់ទំនងជាមួយបណ្តាក្រសួង ស្ថាប័ន ដែលជាសមាជិកគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់

-បំពេញការងារផ្សេងៗទៀតតាមការណែនាំរបស់គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ។

មាត្រា ៦.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីជនដូចក្នុងមាត្រា ១ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ មិថុនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការទទួលស្គាល់សាកលវិទ្យាល័យ ឡាយហ្វ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ២១៥៩ អយក.ឧស ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៧

ស ម្រេ ច

មាត្រា ១ : ទទួលស្គាល់ គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **សាកលវិទ្យាល័យ ឡាយហ្វ** (**Life University**) ហៅកាត់ជាភាសាខ្មែរ " **ស.ឡ** " និងហៅកាត់ជាភាសាអង់គ្លេស " **L.U** "។ សាកលវិទ្យាល័យ ឡាយហ្វ មានទីតាំងស្ថិតនៅ ផ្លូវសេតេ ក្រុម ១០ មណ្ឌល ៣ សង្កាត់លេខ ០២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ និងស្ថិតនៅក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ២ : សាកលវិទ្យាល័យ ឡាយហ្វ ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររង និងបរិញ្ញាបត្រ។ ក្នុងរយៈពេល បីខែ បន្ទាប់ពីថ្ងៃចាប់ដំណើរការបណ្តុះបណ្តាល សាកលវិទ្យាល័យនេះ ត្រូវរៀបចំកម្មវិធីសិក្សាលំអិត តាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៣ : សាកលវិទ្យាល័យ ឡាយហ្វ មានប្រាំ មហាវិទ្យាល័យ :

- មហាវិទ្យាល័យ សិល្បៈ មនុស្សសាស្ត្រ និងភាសា
- មហាវិទ្យាល័យ គណិតសាស្ត្រ និងវិទ្យាសាស្ត្រ
- មហាវិទ្យាល័យ វិទ្យាសាស្ត្រសង្គម
- មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម
- មហាវិទ្យាល័យ គិលានុបដ្ឋាក និងឆ្មប។

ទៅអនាគតសាកលវិទ្យាល័យនេះ អាចបើកសាខា មហាវិទ្យាល័យ មុខជំនាញ កម្រិត ឬថ្នាក់ និង ប្រភេទបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៤ : សាកលវិទ្យាល័យ ឡាយហ្វ មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេច លើគោលនយោបាយ ផែនការអភិវឌ្ឍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ ការរៀបចំតួនាទី ភារកិច្ច រចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង និងការតែងតាំងសាកលវិទ្យាធិការប្រតិបត្តិ ត្រូវកំណត់ដោយប្រធាន ក្រុមប្រឹក្សាភិបាល និងមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៥ : សាកលវិទ្យាធិការប្រតិបត្តិ នៃសាកលវិទ្យាល័យ ឡាយហ្វ មានភារកិច្ចទទួលខុសត្រូវនៅចំពោះមុខ ច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ដោយធានាឱ្យបាននូវសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម និងធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា ជូនក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់។

មាត្រា ៦ : សាកលវិទ្យាល័យ ឡាយហ្វ ត្រូវគោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានដែលពាក់ព័ន្ធនឹងការងារ បណ្តុះបណ្តាលរបស់ក្រសួងអប់រំ យុវជន និងកីឡា និងច្បាប់របស់រាជរដ្ឋាភិបាល សំដៅធានាគុណ ភាពអប់រំ។ ចំពោះការចូលរៀន នៅក្នុងមហាវិទ្យាល័យគិលានុបដ្ឋាក និងឆ្មប សាកលវិទ្យាល័យ ឡាយហ្វ ត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ដែល

កំណត់ អំពីលក្ខខណ្ឌនៃការជ្រើសរើសនិស្សិតឱ្យចូលរៀន នៅតាមគ្រឹះស្ថានឧត្តមសិក្សា និងលក្ខខណ្ឌនៃការបណ្តុះបណ្តាល ក្នុងវិស័យសុខាភិបាល។

មាត្រា ៧ : និស្សិត ដែលបានរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យឡាយហ្វ និងទទួលបានជោគជ័យ ក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងឯកទេស ដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យ ឡាយហ្វ ហើយត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីដែលសាកលវិទ្យាល័យ ឡាយហ្វ បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៨ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសុខាភិបាល ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាល័យ ឡាយហ្វ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាក្រុងព្រះសីហនុ
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦០ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញអនុក្រឹត្យលេខ១៦អនក្រ.បក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានកែសម្រួលជាថ្មី នូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដូចមានគំរូក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។
អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដែលបានផ្តល់តាមខ្លឹមសារអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ នៅមានតំលៃប្រើប្រាស់រហូតដល់អស់សុពលភាព ។

មាត្រា ២: ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើងទៅ ត្រូវមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សម្រាប់សម្គាល់ខ្លួន ដើម្បីប្រើប្រាស់ក្នុងការបំពេញបែបបទរដ្ឋបាលផ្សេងៗ ឬដើម្បីអនុវត្តនីសិទ្ធកាតព្វកិច្ចដទៃទៀត តាមច្បាប់បានកំណត់។

មាត្រា ៣: មិនទាន់ត្រូវបានផ្តល់ ចំពោះជនទាំងឡាយដូចខាងក្រោម :

- កំពុងបំពេញជាបុព្វជិតក្នុងព្រះពុទ្ធសាសនា
- កំពុងអនុវត្តនីទោសតាមសាលក្រមរបស់តុលាការ
- កំពុងឋិតក្នុងមណ្ឌលអប់រំកែប្រែ
- វិកលចរិត
- ជនដែលមានឯកសារផ្លូវការពុំទាន់គ្រប់គ្រាន់ថាខ្លួនមានសញ្ជាតិខ្មែរ ។

មាត្រា ៤ : អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មានសុពលភាព ១០ ឆ្នាំ ចាប់ពីថ្ងៃចេញឱ្យប្រើប្រាស់ ។

មាត្រា ៥ : ពលរដ្ឋខ្មែរទាំងពីរភេទ មានកាតព្វកិច្ច មកធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងត្រូវសរសេរ ឬរាយឆ្លើយអំពីជីវប្រវត្តិផ្ទាល់ខ្លួន និង ឬត្រូវមាន :

- សំបុត្រកំណើតដែលបានបញ្ជាក់ថា សញ្ជាតិខ្មែរ
- សៀវភៅគ្រួសារ (ក៤) ដែលបានបញ្ជាក់ពីសមាជិកសញ្ជាតិខ្មែរ ឬ
- សាលក្រមស្ថាពររបស់តុលាការបញ្ជាក់ទទួលស្គាល់ថា ជននោះកើតពីឪពុក ឬម្តាយ ដែលមានសញ្ជាតិខ្មែរ ឬ
- ព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់សញ្ជាតិខ្មែរ តាមការទាមទារ ឬ សញ្ជាតូបនីយកម្មរបស់សាមីជន ឬ
- ឯកសារ ឬ ភស្តុតាងជាផ្លូវការ ដែលបញ្ជាក់ថា សាមីជនកើតមកពីឪពុក ឬ ម្តាយដែលមានសញ្ជាតិខ្មែរ ។

មាត្រា ៦ : នីតិវិធី លក្ខណ្ឌក្នុងការសុំ ការផ្តល់ និង ការប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

មាត្រា ៧ : អភិបាលខេត្ត ក្រុង ត្រូវទទួលខុសត្រូវក្នុងការដឹកនាំ ចាត់តាំងអនុវត្ត ការងារផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

មាត្រា ៨ : មន្ត្រីមានសមត្ថកិច្ច ដែលផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឱ្យដល់ជនដែលមិនមានសញ្ជាតិខ្មែរ ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ២០ នៃច្បាប់ស្តីពីសញ្ជាតិ ។

មាត្រា ៩ : ជនណាលួចផលិតក្លែងបន្លំ កោសពរប់ រាយការណ៍ ឬ សរសេរឈ្មោះមិនពិត ឬឱ្យគេខ្ចី ឬកាន់ប្រើប្រាស់អត្តសញ្ញាណប័ណ្ណក្លែងក្លាយ ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ២១ នៃច្បាប់ស្តីពីសញ្ជាតិ ។

មាត្រា ១០ : ពលរដ្ឋ ដែលមកសុំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ បឋមតា ទុតិយតា ត្រូវបង់អាករចូលថវិកាជាតិ ។ រយៈពេលចាប់ផ្តើម និងតម្លៃអត្តសញ្ញាណប័ណ្ណ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ។

មាត្រា ១១ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពី អនុក្រឹត្យនេះ ទុកជានិរាករណ៍ ។

មាត្រា ១២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តន៍អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានគោរពជូន

សម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៥៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកំណត់ក្របខ័ណ្ឌមន្ត្រីក្រមការ និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម តាមលក្ខន្តិកៈដោយឡែក

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទ ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥២ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម
- បានឃើញសារាចរណែនាំលេខ ០២ សរណន ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការកំណត់ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលតាមលក្ខន្តិកៈដោយឡែក
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

សម្រេច

មាត្រា ១.-

ត្រូវបានកំណត់ជាក្របខ័ណ្ឌមន្ត្រីក្រមការ និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិនាយក្រមការ នូវមន្ត្រីរាជការស៊ីវិលរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដូចមានរាយនាមខាងក្រោម ៖

១	ញ៉ៀម សេដ្ឋា	ស	នាយក្រមការ	ថ្នាក់លេខ ២
២	មឡ្យ រិទ្ធី	ប	នាយក្រមការ	ថ្នាក់លេខ ២
៣	ជា សូផាត	ប	នាយក្រមការ	ថ្នាក់លេខ ២
៤	អ៊ុង ឆេង	ប	នាយក្រមការ	ថ្នាក់លេខ ២
៥	អ៊ឹម សុខុម	ប	នាយក្រមការ	ថ្នាក់លេខ ២
៦	កែប ឈៀប	ប	នាយក្រមការ	ថ្នាក់លេខ ២
៧	តូច សារ៉ុន	ប	នាយក្រមការ	ថ្នាក់លេខ ២
៨	ឆេព ធីរៈ	ប	នាយក្រមការ	ថ្នាក់លេខ ៣
៩	ហុង ប៊ុនធី	ប	នាយក្រមការ	ថ្នាក់លេខ ៣
១០	ឆេង ឡេន	ប	នាយក្រមការ	ថ្នាក់លេខ ៣
១១	ស គន្ធា	ប	នាយក្រមការ	ថ្នាក់លេខ ៣
១២	អនន្ត អភិជន	ប	នាយក្រមការ	ថ្នាក់លេខ ៤
១៣	មាស ប៊ុណ្ណា	ប	នាយក្រមការ	ថ្នាក់លេខ ៤
១៤	មាស ចំរើន	ប	នាយក្រមការ	ថ្នាក់លេខ ៤
១៥	តែន ឆេងហុង	ស	នាយក្រមការ	ថ្នាក់លេខ ៤
១៦	អ៊ិន សារី	ស	នាយក្រមការ	ថ្នាក់លេខ ៤
១៧	ឡូច ឫទ្ធី	ប	នាយក្រមការ	ថ្នាក់លេខ ៤
១៨	សុខ្ល ជយ	ប	នាយក្រមការ	ថ្នាក់លេខ ៥
១៩	ហួយ ស៊ីខួន	ប	នាយក្រមការ	ថ្នាក់លេខ ៥
២០	ខ្លូត គុន	ប	នាយក្រមការ	ថ្នាក់លេខ ៥
២១	ស្រី សារឿន	ប	នាយក្រមការ	ថ្នាក់លេខ ៥
២២	ព្រំ គឹមហឿន	ស	នាយក្រមការ	ថ្នាក់លេខ ៥
២៣	ប្រាក់ គារ៉ាវុធ	ប	នាយក្រមការ	ថ្នាក់លេខ ៥
២៤	ឡៀង សារិទ្ធ	ប	នាយក្រមការ	ថ្នាក់លេខ ៥
២៥	ឡុង សម្បត្តិ	ប	នាយក្រមការ	ថ្នាក់លេខ ៥
២៦	ស៊ុន ម៉េងហោ	ប	នាយក្រមការ	ថ្នាក់លេខ ៥

២៧	ឈឿង និមុល	ប	នាយក្រមការ	ថ្នាក់លេខ ៥
២៨	អាឈី រ៉ូណេ	ប	នាយក្រមការ	ថ្នាក់លេខ ៥
២៩	អ៊ី ប៊ុនធឿន	ប	នាយក្រមការ	ថ្នាក់លេខ ៥
៣០	កែម ធុរ្សី	ប	នាយក្រមការ	ថ្នាក់លេខ ៥
៣១	ប្រាក់ សៀងអាន	ប	នាយក្រមការ	ថ្នាក់លេខ ៦
៣២	គីម ណារី	ស	នាយក្រមការ	ថ្នាក់លេខ ៦
៣៣	ម៉ែន ម៉ុន	ប	នាយក្រមការ	ថ្នាក់លេខ ៦
៣៤	ជីវ ផារី	ប	នាយក្រមការ	ថ្នាក់លេខ ៦
៣៥	ញាន និត្យចិន្តា	ស	នាយក្រមការ	ថ្នាក់លេខ ៦
៣៦	ពៅ ស៊ីធុតា	ស	នាយក្រមការ	ថ្នាក់លេខ ៦
៣៧	ផាន់ ណារឿន	ស	នាយក្រមការ	ថ្នាក់លេខ ៦

មាត្រា ២.-

ត្រូវបានកំណត់ជាក្របខ័ណ្ឌមន្ត្រីក្រមការ និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិក្រមការដើមខ្សែ នូវមន្ត្រីរាជការស៊ីវិលរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដូចមានរាយនាមខាងក្រោម ៖

១	វុំ យឿប	ប	ក្រមការដើមខ្សែ	ថ្នាក់លេខ ៤
២	សៅ សារឿន	ស	ក្រមការដើមខ្សែ	ថ្នាក់លេខ ៤
៣	ថន ញ៉ី	ប	ក្រមការដើមខ្សែ	ថ្នាក់លេខ ៤
៤	សុខ សម្បត្តិ	ប	ក្រមការដើមខ្សែ	ថ្នាក់លេខ ៥
៥	គីម យ៉ាត	ស	ក្រមការដើមខ្សែ	ថ្នាក់លេខ ៥
៦	មុត ណារី	ស	ក្រមការដើមខ្សែ	ថ្នាក់លេខ ៥
៧	នួច ធុតា	ប	ក្រមការដើមខ្សែ	ថ្នាក់លេខ ៥
៨	ហៃ ហន	ប	ក្រមការដើមខ្សែ	ថ្នាក់លេខ ៥
៩	ចាន់ សារី	ប	ក្រមការដើមខ្សែ	ថ្នាក់លេខ ៥
១០	ឌួន ដារ៉ារិទ្ធ	ប	ក្រមការដើមខ្សែ	ថ្នាក់លេខ ៥
១១	ឆេង ខា	ប	ក្រមការដើមខ្សែ	ថ្នាក់លេខ ៥
១២	សុខ ខា	ប	ក្រមការដើមខ្សែ	ថ្នាក់លេខ ៥

១៣	ហួត ចាន់យ៉ារ៉េត	ប	ក្រុមការងារខ្មែរ	ថ្នាក់លេខ ៦
១៤	សេង ហ៊ុធិន	ប	ក្រុមការងារខ្មែរ	ថ្នាក់លេខ ៦
១៥	ហែម សំបូរ	ប	ក្រុមការងារខ្មែរ	ថ្នាក់លេខ ៦
១៦	ម៉ាន់ សំបូរ	ប	ក្រុមការងារខ្មែរ	ថ្នាក់លេខ ៦
១៧	ចាន់ សុគុន	ប	ក្រុមការងារខ្មែរ	ថ្នាក់លេខ ៦
១៨	ខៀវ ហឿន	ប	ក្រុមការងារខ្មែរ	ថ្នាក់លេខ ៦
១៩	គង់ ឡឿន	ប	ក្រុមការងារខ្មែរ	ថ្នាក់លេខ ៦
២០	នុត សាំងទេង	ប	ក្រុមការងារខ្មែរ	ថ្នាក់លេខ ៧
២១	នុយ ឆេព	ស	ក្រុមការងារខ្មែរ	ថ្នាក់លេខ ៧
២២	ពេជ្រ គីត	ប	ក្រុមការងារខ្មែរ	ថ្នាក់លេខ ៨
២៣	គីម ទ៊ុន	ប	ក្រុមការងារខ្មែរ	ថ្នាក់លេខ ៩
២៤	ឆន ប៊ូរ៉ាន់	ប	ក្រុមការងារខ្មែរ	ថ្នាក់លេខ ៩
២៥	ជុំ ដឹប	ប	ក្រុមការងារខ្មែរ	ថ្នាក់លេខ ៩
២៦	រិន ពិទូរ្យ	ស	ក្រុមការងារខ្មែរ	ថ្នាក់លេខ ៩
២៧	ឈុន នារី	ស	ក្រុមការងារខ្មែរ	ថ្នាក់លេខ ៩
២៨	នួច ឌីណា	ស	ក្រុមការងារខ្មែរ	ថ្នាក់លេខ ៩
២៩	ប្រាក់ ណារិន	ស	ក្រុមការងារខ្មែរ	ថ្នាក់លេខ ៩
៣០	អ៊ុច ម៉ៅ	ប	ក្រុមការងារខ្មែរ	ថ្នាក់លេខ ៩
